ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ២០ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការពន្យារពេលរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម្រាប់ឆ្នាំសិក្សា ២០១៩-២០២០

ក្នុងឆ្នាំសិក្សា ២០១៩-២០២០ នេះ ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តអនុវត្តកំណែទម្រង់ការប្រឡងគ្រប់ប្រភេទ ស្របតាមគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន។ ក្នុងស្មារតីចូលរួមបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ក្រសួងសូមធ្វើការណែនាំដូចខាងក្រោម៖

១. ពន្យារពេលរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ដែលគ្រោងនឹងប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ ក្រសួងនឹងកំណត់ និងជម្រាបជូនអំពីកាលបរិច្ឆេទនៃសម័យប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ នៅពេលក្រោយ។

២. ពន្យារពេលរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដែលគ្រោងនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០ ដល់ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ ក្រសួងនឹងកំណត់ និងជម្រាបជូនអំពីកាលបរិច្ឆេទនៃសម័យប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅពេលក្រោយ។

៣. កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះឈ្មោះប្រឡង និងការផ្តល់សំណុំលិខិតចុះឈ្មោះប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម្រាប់បេក្ខជនគ្រប់ប្រភេទ ( ទាំង Hard និង Soft copy ) ត្រូវបញ្ជូនមកក្រសួង ( នាយកដ្ឋានកិច្ចការប្រឡង ) តាមកាលកំណត់ ដើម្បីរៀបចំការប្រឡងនៅពេលក្រោយ។

៤. សិស្សានុសិស្សទាំងអស់ត្រូវធ្វើស្វ័យសិក្សានៅតាមផ្ទះ ដោយប្រើប្រាស់សៀវភៅសិក្សាគោល និងតាមរយៈប្រព័ន្ធអេឡិចត្រូនិក(E-Learning) ដែលមាននៅក្នុងគេហទំព័រផ្លូវការរបស់ក្រសួង រួមមាន៖ YouTube ផ្លូវការរបស់ក្រសួង (www.youtube.com/moeys), Facebook ផ្លូវការរបស់ក្រសួង (www.facebook.com/moeys.gov.kh), មជ្ឈមណ្ឌលសិក្សាអេឡិចត្រូនិក elearning.moeys.gov.kh រួមជាមួយនឹងប្រព័ន្ធ E-School Cambodia និងប្រព័ន្ធ Wiki School ទាំងលើប្រព័ន្ធដំណើរការទូរស័ព្ទដៃ Android និង iOS និងការចាក់ផ្សាយតាមទូរទស្សន៍នានា ដូចជា ទូរទស្សន៍អប្សារាប៉ុស្តិ៍លេខ១១, ទូរទស្សន៍ OneTV ប៉ុស្តិ៍លេខ៦, ទូរទស្សន៍ខ្សែកាប SkyOne ប៉ុស្តិ៍លេខ៣៥, ទូរទស្សន៍ Wiki School TV ជាដើម និងពីប្រភពផ្សេងៗទៀត។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់គ្រប់ការិយាល័យជំនាញនៃមន្ទីរ គ្រឹះស្ថានមធ្យមសិក្សា និងអ្នកពាក់ព័ន្ធ ព្រមទាំងចូលរួមសហការ ជំរុញ តាមដានជាប់ជាប្រចាំ និងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ១៥កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-សាលារាជធានី ខេត្ត

-គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

-គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង

- ដើម្បីជូនជ្រាបជាព័ត៌មាន-

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

-ដើម្បីអនុវត្ត-

-កាលប្បវត្តិ

-ឯកសារ នាយកដ្ឋានកិច្ចការប្រឡង